# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខៈ... ស.ខ.ក.ក.

## លិខិតរំលែកមរណទុក្ខ
## ជូន
## ក្រុមគ្រួសារសពលោក ស៊ាន ប៉េងសែ
### ប្រធានគណៈកម្មាធិការព្រំដែនកម្ពុជាប្រចាំប្រទេសបារាំង និងពិភពលោក
### និងជាអតីតរដ្ឋមន្ត្រីនៃក្រសួងឧស្សាហកម្ម រ៉ែ និងសិប្បកម្ម

ក្នុងនាមថ្នាក់ដឹកនាំ សមាជិកសហគមន៍ខ្មែរកម្ពុជាក្រោម និងក្នុងនាមខ្ញុំផ្ទាល់មានសេចក្តីក្រៀមក្រំយ៉ាងក្រៃលែងនៅពេលដែលបានទទួលដំណឹងថា លោក ស៊ាន ប៉េងសែ បានទទួលមរណភាពនៅប្រទេសបារាំង កាលពីថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៣ ខែមករា គ.ស.២០១៨ វេលាម៉ោង ៤ ទាបភ្លឺ ក្នុងជន្មាយុ ៨២ឆ្នាំ។

មរណភាពរបស់លោក ស៊ាន ប៉េងសែ គឺជាការបាត់បង់លោកឪពុក បាត់បង់ជីតាដ៏ជាទីគោរព និងជាទីស្រឡាញ់ ជាការបាត់បង់បញ្ញវន្តខ្មែរស្នេហាជាតិមួយរូប និងជាការបាត់បង់ធនធានមនុស្សដ៏កម្រ ដែលមានឯកទេសខាងព្រំដែនដ៏សំខាន់បំផុត។

លោក ស៊ាន ប៉េងសែ គឺជាវីរជនខ្មែរស្នេហាជាតិមួយរូបដ៏បរិសុទ្ធ ដែលស្ទើរពេញក្នុងមួយជីវិតរបស់លោកបានលះបង់ដើម្បីជាតិដោយគ្មានរួញរា មិនថារស់នៅទីណា ជីវភាពលំបាកបែបណានោះទេ ជាពិសេសបានបង្កើតគណៈកម្មាធិការព្រំដែន បានធ្វើឲ្យប្រជារាស្ត្រខ្មែរយល់ច្បាស់អំពីព្រំដែនទឹកដីរបស់ខ្លួន និងការបាត់បង់ទឹកដីយ៉ាងពិតប្រាកដ ប្រសិនបើការកំណត់ព្រំដែនណាមួយមិនបានធ្វើទៅតាមឯកទេសស្រាវជ្រាវរបស់លោកទេនោះ។

ក្នុងនាមជាកូនខ្មែរ ទោះបីលោកបានរត់ភៀសខ្លួនពីអំណាចផ្តាច់ការ ទៅរស់នៅប្រទេសបារាំងក្តី មានវ័យចាស់ជរាក្តី លោកមិនដែលបោះបង់ឧត្តមគតិស្នេហាជាតិម្តងណាឡើយ គឺលោកនៅតែបន្តសកម្មភាពផ្សេងៗ ដើម្បីជួយសង្គ្រោះប្រទេសជាតិ និងរក្សាយ៉ាងខ្ជាប់ខ្ជួននូវទំនៀមទម្លាប់វប្បធម៌ដ៏ល្អផូរផង់របស់ខ្មែរជានិច្ច។

សហគមន៍ខ្មែរកម្ពុជាក្រោមមានសេចក្តីសោកស្តាយយ៉ាងក្រៃលែងនិងសូមចូលរួមរំលែកមរណទុក្ខយ៉ាងក្រៀមក្រំជាទីបំផុតជាមួយក្រុមគ្រួសារនៃសពទាំងមូល។

សហគមន៍ខ្មែរកម្ពុជាក្រោមសូមវាយតម្លៃយ៉ាងខ្ពស់ចំពោះវីរភាពស្នេហាជាតិដ៏បរិសុទ្ធរបស់ លោក និងចាត់ទុកជាវីរជនគំរូសម្រាប់សហគមន៍ខ្មែរកម្ពុជាក្រោម។

សហគមន៍ខ្មែរកម្ពុជាក្រោម សូមបួងសួងឲ្យវិញ្ញាណក្ខន្ធ លោក ស៊ាន ប៉េងសែ បានទៅសោយសុខក្នុងសុគតិភពកុំបីខាន និងសូមជូនពរគ្រួសារនៃសពបានប្រកបទៅដោយពុទ្ធពរទាំង៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមក្រុមគ្រួសារនៃសពទាំងអស់ ទទួលនូវការចូលរួមរំលែកនូវមរណទុក្ខដោយស្មោះអស់ពីដួងចិត្តពីយើងខ្ញុំ៕

រាជធានីភ្នំពេញ, ថ្ងៃ ៩កើត ខែមាឃ ឆ្នាំរកា នព្វស័ក
ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី២៥ ខែមករា គ.ស.២០១៨
ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម

**ថាច់ សេដ្ឋា**
អតីតសមាជិកព្រឹទ្ធសភា

Website: www.khmerkromngo.org
ទីស្នាក់ការ : ផ្ទះលេខ ៧២ ផ្លូវលេខ ៤២៦A ភូមិគោកឃ្លាំង សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ : (៨៥៥) ០១២ ៩០៨ ៨៨២ / ៩៣ ៤៧ ៤៧ ០៦
E-mail: thachsetha13@gmail.com, Website: khmerkromngo.org